# មត៌កនិងសិល្បៈនៅលើព្រះវិហារបុរាណវត្តកណ្ដាល

ខ្ញុំធ្លាប់បានចុះផ្សាយម្ដងរួចមកហើយអំពីព្រះវិហារបុរាណវត្តកណ្ដាល (ឬវត្តសំរិទ្ធិជយារាម) ដែលស្ថិតនៅតាមដងទន្លេធំ(ទន្លេមេគង្គ) ក្នុងឃុំកោះអណ្ដែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។[1] ការផ្សព្វផ្សាយគ្រានោះ ជាព័ត៌មានទូទៅជូនសាធារណៈជនបានស្គាល់ទីតាំងភូមិសាស្ត្រវត្ត ហើយអាចទៅសិក្សាស្វែងយល់បន្ថែមនូវសំណង់បេតិកភណ្ឌព្រះវិហារតូចមួយ ដែលមានភ័ព្វបុណ្យគង់វង្សរស់ពីសង្គ្រាម សឹងប្រកបដោយគំនូរ និងក្បាច់ចម្លាក់លម្អវិចិត្រប្រណីតដ៏ល្អក្រៃលែងគួរឲ្យស្ញប់ស្ញែងពន់ពេក នឹងរកសំណង់សម័យទំនើបប្រៀបពុំបាន។ ក្នុងអត្ថបទនេះ ខ្ញុំសូមលើកបង្ហាញបន្ថែមទៀតនូវមត៌កសិល្បៈដែលដូនតាមានចិត្តសទ្ធាបុណ្យខិតខំកសាង ថែទាំជួសជុល រក្សាការពារចារឹកទុកផ្ដាំតមករាប់ជំនាន់ ជាពិសេសគឺគំនូរបុរាណលើពិតានឈើនៃព្រះវិហារ (រូបលេខ១)។



រូបលេខ១ ព្រះវិហារបុរាណ និងព្រះវិហារថ្មី នៃវត្តកណ្ដាលសង់លើខឿនតែមួយ

[1] សូមអាន៖ "ព្រះវិហារចាស់នៅវត្តកណ្ដាល" ផ្សាយលើគំ https://ams.com.kh/khmercivilization/detail/28746

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារបុរាណវត្តកណ្តាល សង់នៅលើខឿនកម្ពស់ត្រឹមចង្កេះ ទទឹងប្រហែល៩ម៉ែត្រកន្លះ និងបណ្តោយប្រហែល១៩ម៉ែត្រកន្លះ។ ព្រះវិហារនេះសង់អំពីឈើ សសរ៣២ដើម ចែកជា៣ល្វែង ដំបូលប្រក់ក្បឿងស្រកាលេញជាប្រភេទព្រះវិហារជហ្វាបួន ជញ្ជាំងជុំវិញរៀបឥដ្ឋ (រូបលេខ២-៣)។ បើយកមូលដ្ឋានតាមសាវតារវត្តឱ្យដឹងថា វត្តកណ្តាលមានឈ្មោះដើមហៅ "វត្តចុងកោះអណ្តែត"។ តាមការសិក្សារបស់ *Danielle* និង *Dominique-Pieree Guéret* យល់ថាព្រះវិហារនេះកសាងក្នុងឆ្នាំ១៩០៩ ហើយគំនូរលើជញ្ជាំងគូរនៅក្នុងឆ្នាំ១៩៦៤។[2] ប៉ុន្តែបើយោងតាមផ្ទាំងចារឹកជាប់បល្ល័ង្កព្រះជីវ៍ គេដឹងថាទីវត្តនេះកសាងតាំងពីពុទ្ធសករាជ២៤៣៨ (ឆ្នាំ១៨៩៥) ហើយព្រះវិហារកសាងក្នុងពុទ្ធសករាជ២៤៤២ (ឆ្នាំ១៨៩៩) (រូបលេខ៤)។ កាលបរិច្ឆេទនេះ គឺចាស់ជាងសេចក្តីយល់ឃើញរបស់អ្នកស្រាវជ្រាវ *Danielle* និង *Dominique-Pieree Guéret* ជាង១ទសវត្សរ៍។ មិនតែប៉ុណ្ណោះនៅលើជញ្ជាំងខាងកើត ផ្នែកខាងក្នុងមានចំណារមួយផ្ទាំងតូចទៀតមានសេចក្តីខ្ចីថា "បានរូស(រុះ)រើជញ្ជាំងចាស់ធ្វើជាថ្មីឡើងវិញពីឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥០៨"។ តាមសេចក្តីនេះមានន័យថាជញ្ជាំងព្រះវិហារសព្វថ្ងៃរុះរើរៀបថ្មីក្នុងឆ្នាំ១៩៦៥។ លើសពីនេះ គេដឹងថា ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) ពុទ្ធបរិស័ទបានរួមគ្នាជួសជុលកែលម្អព្រះវិហារនេះ និងជួសជុលសាងគំនូររឿងពុទ្ធប្រវត្តិតាមជញ្ជាំងជុំវិញ ទុកជាកេរបុរាណសម្រាប់អ្នកជំនាន់ក្រោយ។





*រូបលេខ២-៣ ព្រះវិហារបុរាណវត្តកណ្តាល (មើលពីជ្រុងពាយ័ព្យ និងមើលពីខាងលិច)*

---

[2] *Danielle* និង *Dominique-Pieree Guéret 2017: 109*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៤ ផ្នែកខ្លះនៃផ្ទាំងចារឹក និងចំណារខាងមុខបល្ល័ង្កព្រះជីវ៍ (ផ្នែកខ្លះរលុប)

បន្ថែមពីលើនេះ បើស្រង់ខ្លឹមសារ៨បន្ទាត់ចារលើជញ្ជាំងខាងលិច ចំខាងក្រោយព្រះជីវ៍បញ្ជាក់ថា នៅឆ្នាំ១៩៨១ ពុទ្ធបរិស័ទបានរួមគ្នាកសាងព្រះវិហារជាលើកទី២ ទុកជាដំណែលបន្ទាប់ពីសង្គ្រាមបានបញ្ចប់ ដោយមានខ្លឹមសារឧទ្ទិសកុសលបុណ្យដល់ម្ចាស់សទ្ធា និងថែមទាំងឧទ្ទិសកុសលដល់កូនចៅគ្រប់ជំនាន់ថា "(១)សូមបង្អោនកាយវាចាចិត្តគោរពឧទ្ទិស្ស(ឧទ្ទិស)ការកសាងលើកទី២នេះ បូជាចំពោះបុព្វបុរស (២)ទាំងអស់មានព្រះតេជគុណគម្ពីរោ ឯក អ៊ីង ជាមគ្គុទ្ទេសដឹកនាំ បានកសាងកេរ្តិ៍តំណែល(កេរដំណែល) (៣) ទុកដល់យើងខ្ញុំជាកូនចៅតជំនាន់គោរពបូជា។ នឹងឧទ្ទិស្ស(ឧទ្ទិស)ជូនកូនចៅពុទ្ធបរិស័ទ្យ(បរិស័ទ)ពល់ជំ (៤)នាន់តទៅខាងមុខ សូមលោកអ្នកបានសំរេចប្រយោជន៍នៅ(នូវ)សេចក្ដីសុខគ្រប់ប្រការ។ល។ (៥) ធ្វើនៅថ្ងៃអង្គារ ៦រោជ(រោច) ខែកត្តិក ឆ្នាំរកាត្រីស័ក្ស(ស័ក) ព.ស.២៥២៤។ (៦) តំណាងពុទ្ធបរិស័ទភូមិចុងកោះអណ្តែត (៧)ឧបាសក សូ អ៊ុំ អាចារ្យសំរាប់វត្ត ឧបាសក មាឃ យ៉ាន់ ព្រិឌ្ឍាចារ្យ(ព្រឹទ្ធាចារ្យ)វត្ត (៨)អ្នកសរសេរបណ្ឌិតផាន់ ធន់, ញ៉ែម អ៊ុល (ត្រា)" (រូបលេខ៥)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥ សេចក្តីចារឹកពីការជួសជុលព្រះវិហារឡើងវិញនៅឆ្នាំ១៩៨១

ចំណែកឯខ្លឹមសារលើជញ្ជាំងខាងកើត ចាររៀបរាប់អំពីចិត្តសទ្ធារបស់ពុទ្ធបរិស័ទជិតឆ្ងាយ ដែលបានមូលមាត់គ្នាខិតខំចាត់ចែងប្រាក់ ជួយកម្លាំង ជួយម្ហូបអាហារ ដើម្បីជួសជុលព្រះវិហារ និងសាងគំនូរឲ្យល្អឡើងវិញក្នុងឆ្នាំ១៩៨៣-១៩៨៤ មានសេចក្តីថា "យើងខ្ញុំជាពុទ្ធបរិសទ្យ (បរិស័ទ)ចំណុះជើងវត្ត និងពីទីដំទៃ(ដទៃ)ខ្លះ មានសទ្ធាជ្រះថ្លារួបរួមគ្នាក៏សាង(កសាង)គំនូ(រ)រឿងពុទ្ធនៅជញ្ជាំងព្រះវិហារ និងសសរ ឧទ្ទិសថ្វាយជាពុទ្ធបូជា ចាប់ធ្វើនៅថ្ងៃច័ន្ទ ៨រោច ខែទុតិយាសាឍ(ឍ) ឆ្នាំកុរ បញ្ចសក្ស(ស័ក) ព.ស.២៥២៦ ត្រូវនិងថ្ងៃទី១ ខែសីហា ឆ្នាំ១៩៨៣. ក្នុងការក៏សាង(កសាង)នេះ ពុទ្ធបរិសទ្យ(បរិស័ទ)ខ្លះមានសទ្ធាចេញប្រាក់ជួលជាងគូ(រ)តាមផ្ទាំងមួយៗ គ្រួសារមួយៗ។ ពុទ្ធបរិសទ្យ(បរិស័ទ)ខ្លះមានសទ្ធាឧបត្ថម្ភជាងទទួលវេនធ្វើម្ហូបអាហារ ដរាបបានហើយស្រេចនៅថ្ងៃសុក្រ ១៥កើត ខែផល្គុន ឆ្នាំដដែល ត្រូវនិងថ្ងៃ១៦ ខែមីនា ១៩៨៤ យើងខ្ញុំបានចុះនាមឈ្មោះលោកអ្នកតាមផ្ទាំង និងសសរគ្រប់ទាំងអស់។ យើងខ្ញុំសូមអភ័យទោសដោយពុំបានចុះនាមឈ្មោះឈោកនាក់(លោកអ្នក)ទទួលធ្វើវេនជាងក្នុងទីនេះ។ សូមពុទ្ធបរិសទ្យ(បរិស័ទ)ទាំងអស់ត្រេកអ(រ) អនុមោទនាទទួលយកភាគផលបុណ្យកុសលតាមសទ្ធារៀងខ្លួន : ទីបំផុតសូមពុទ្ធបរិសទ្យ(បរិស័ទ)ទាំងអស់សំរេចមគ្គផល ព្រះនិព្វាន កំបីឃ្លាត។ "អនុមោទនា" (រូបលេខ៦)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៦ សេចក្តីចារឹកពីចិត្តសទ្ធាជួសជុលសាងគំនូរក្នុងព្រះវិហារ

ដោយឡែកចំពោះផ្នែកសិល្បៈក្បាច់រចនា និងគំនូរខាងក្នុងព្រះវិហារ នៅចុងខាងលិចល្វែងគ្រឹះមានបល្ល័ង្កខ្ពស់មួយយ៉ាងល្អវិចិត្រតម្កល់ព្រះបដិមាព្រះជីវ័។ ខឿនបល្ល័ង្កមានគំនូរពាក់ព័ន្ធរឿងពុទ្ធប្រវត្តិ និងចំណារសារបានវត្តចារនៅខាងមុខ ដែលនាំឱ្យដឹងថាព្រះជីវ័សព្វថ្ងៃជួសជុលឡើងវិញក្នុងព.ស.២៥២៤ (ឆ្នាំ១៩៨១)។ ចំណុចពិសេសនៃបល្ល័ង្កនេះ គឺនៅលើតួបល្ល័ង្ករចនាជាក្បាច់ភ្ញី និងរូបផ្សេងៗតាមរបៀប "គំនូរបុក" ដែលនិយមក្នុងសិល្បៈខ្មែរតាំងពីដើមសតវត្សរ៍ទី២០ (រូបលេខ២៧-៨)។[3]



រូបលេខ២៧-៨ បល្ល័ង្កព្រះជីវ័រចនាលម្អដោយគំនូរបុក

[3] សូមអានបន្ថែម៖ ព្រាប ចាន់ម៉ារ៉ា ២០០៩-២០១០: ៣៨-៤១

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះពិតានព្រះវិហារនេះ គឺជាពិតានឈើដែលរៀបចំឡើងតែនៅលើចន្លោះល្វែងគ្រឹះប៉ុណ្ណោះ។ គំនូរនៃពិតាន ជាប្រភេទគំនូរបុរាណដែលអ្នកខ្លះយល់ថាគូរតាំងពីពេលសង់ព្រះវិហារ ហើយគង់វង្សដល់បច្ចុប្បន្ន។ ប្រធានបទសំខាន់ៗគូរលើពិតាន គឺរូបព្រះអាទិត្យ ព្រះចន្ទ្រ និងទេពនិករនានាហោះហើរលើអាកាស ដែលកម្រនឹងឃើញមាននៅតាមបណ្ដាព្រះវិហារដទៃ (រូបលេខ៩-១២)។[4]



រូបលេខ៩-១០ គំនូរបុរាណលើពិតានបង្ហាញពីទេពនិករលើអាកាស



រូបលេខ១១-១២ គំនូរបុរាណលើពិតានបង្ហាញពីព្រះអាទិត្យ និងព្រះចន្ទ្រ

[4] សូមអានបន្ថែម៖ សាន ផល្លា ២០០៥-២០០៦: ៨៧-៨៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*គំនូរលើជញ្ជាំងជុំវិញ គូរឡើងវិញក្នុងឆ្នាំ១៩៨៣-១៩៨៤ រៀបរាប់អំពីរឿងពុទ្ធប្រវត្តិ។ ប៉ុន្តែគំនូរត្រង់ព្រះអង្គទ្រង់ប្រសូត្រ គេគូរពួកទេពនិករនៅផ្នែកម្ខាង ឯផ្នែកខាងទៀតប្រហែលគេគូរបញ្ជាក់ព្រះវត្តមានក្សត្រ និងវត្តមានអ្នកនគរផ្សេងៗ ដែលក្នុងនោះវិចិត្រករគូរបង្ហាញព្រះឆាយាលក្ខណ៍ **ព្រះបរមរតនកោដ្ឋ** ទ្រង់គ្រឿងព្រះពស្ត្រក្បិនពណ៌លឿង ព្រះភូសាកុតកត្រង់ តែពុំមានព្រះសុពណ៌បាទ (រូបលេខ១១៣)។ រីឯគំនូរព្រះអង្គទ្រង់បិណ្ឌបាត្រនៅនគរកបិលភស្តុ ក្រៅពីបង្ហាញឱ្យព្រះវត្តមានព្រះសុទ្ធោទន៍យាងថ្វាយបង្គំ វិចិត្រករបានគូរបញ្ចូលសំណង់ខ្លះមានលក្ខណៈស្មើរដូចព្រះបរមរាជវាំងក្រុងចតុមុខ។ មិនតែប៉ុណ្ណោះអ្វីដែលគួរឱ្យចាប់អារម្មណ៍ គឺការគូរបង្ហាញទង់ជាតិនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅខាងចុងនៃជួរភិក្ខុទាំងឡាយ (រូបលេខ១១៤)។*





*រូបលេខ១១៣ កាលព្រះអង្គទ្រង់ប្រសូត*

*រូបលេខ១១៤ ព្រះអង្គបិណ្ឌបាត្រនៅក្រុងកបិលភស្តុ*

*សង្ខេបសេចក្ដីមក មត៌កដែលជាប់នៅនឹងសំណង់ព្រះវិហារបុរាណវត្តកណ្ដាល គឺពិតជាមានតម្លៃធំធេង ទាំងជាប្រវត្តិសាស្ត្រនៃការកសាងបូជនីយដ្ឋានពុទ្ធសាសនា និងតម្លៃសីលធម៌ដ៏ថ្លៃថ្នូរបស់ដូនតា ដែលគោរពបុណ្យកេរបុរាណ ខិតខំចាត់ចែងជួសជុលថែទាំរហូតមក។ មិនតែប៉ុណ្ណោះ ព្រះវិហារនេះក៏ជាបណ្ដុំមត៌កសិល្បៈគំនូរបុរាណប្រកបដោយទេពកោសល្យ និងទឹកដៃសិល្បៈយ៉ាងល្អឆើត និងគំនូរបង្ហាញពីចំណុចពិសេសដែលវិចិត្រករគូរបញ្ចូលតួអង្គអតីតព្រះមហាក្សត្រ និងទិដ្ឋភាពសង្គមខ្មែរខ្លះទៅក្នុងគំនូរដែលជាសេរីភាពសិល្បៈដ៏ទូលំទូលាយគួរឲ្យកត់សម្គាល់៕*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០០៩-២០១០, "គំនូរបុក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៥. ទំ.៣៨-៤១*, Friends of Khmer Culture, ភ្នំពេញ

សាន ផល្លា

២០០៥-២០០៦, "ព្រះអាទិត្យនិងព្រះចន្ទនៅក្នុងសង្គមខ្មែរ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២១. ទំ.៨៧-៨៩*, Friends of Khmer Culture, ភ្នំពេញ

ហៀន សុវណ្ណមរកត

២០២៣, "ព្រះវិហារចាស់នៅវត្តកណ្ដាល", ផ្សាយលើគំ https://ams.com.kh/khmercivilization/detail/28746 (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣)

Daniell Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions